ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៧៤៧ កសក

# សេចក្តីណែនាំ
# ស្តីពី
# វិធានការពង្រឹងការត្រួតពិនិត្យ គុណភាពសម្ភារកសិកម្ម

បច្ចុប្បន្ននេះ ការតម្រង់ទិសឱ្យកសិករមានការយល់ដឹងក្នុងការប្រើប្រាស់សម្ភារកសិកម្មដែលធានាគុណភាព និង ត្រឹមត្រូវតាមក្បួនខ្នាតបច្ចេកទេស គឺជាសកម្មភាពសំខាន់មួយដែលរួមចំណែកក្នុងការជំរុញផលិតកម្មកសិកម្ម ក្នុងគោលបំណងធានានូវផលប្រយោជន៍របស់កសិករក្នុងផលិតកម្មកសិកម្ម ដើម្បីអាចទទួលយកឱកាសប្រកួតប្រជែងទីផ្សារ ជាពិសេសបង្កើនការនាំចេញកសិផលស្របតាមអាទិភាពនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងក្របខណ្ឌអភិវឌ្ឍន៍វិស័យកសិកម្ម។

កន្លងមករាជរដ្ឋាភិបាលបានដាក់ចេញនូវសារាចរ លេខ ០៣ សរ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីវិធានការពង្រឹងប្រព័ន្ធគ្រប់គ្រង និង ត្រួតពិនិត្យការធ្វើអាជីវកម្មសម្ភារកសិកម្ម ដើម្បីជាវិធានការបន្ថែមលើលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមានសម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ សហការអនុវត្តឱ្យបានល្អប្រសើរក្នុងការគ្រប់គ្រងសម្ភារកសិកម្ម។

ដើម្បីចូលរួមអនុវត្តសកម្មភាពជាយុទ្ធសាស្ត្រនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សូមធ្វើការណែនាំបន្ថែម ចំពោះមន្ទីរកសិកម្មរាជធានី ខេត្ត នូវវិធានការអនុវត្តក្នុងការពង្រឹងការត្រួតពិនិត្យគុណភាពសម្ភារកសិកម្ម ដូចខាងក្រោម:

១-ត្រូវក្តាប់ឱ្យបាននូវមូលដ្ឋានអាជីវកម្ម និង រាល់សកម្មភាពធ្វើអាជីវកម្មសម្ភារកសិកម្មក្នុងរាជធានី ខេត្ត សាមី ដោយត្រូវមានសម្រង់ស្ថិតិបញ្ជាក់ពីស្ថានភាពអនុវត្តច្បាប់របស់មូលដ្ឋានអាជីវកម្មនីមួយៗឱ្យបានច្បាស់លាស់។

២-ត្រូវជំរុញការងារផ្សព្វផ្សាយអប់រំ ណែនាំដល់អាជីវករសម្ភារកសិកម្មគ្រប់ប្រភេទ ក្នុងមូលដ្ឋាន ឱ្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមនីតិវិធី និង ដាក់វិធានការឱ្យអាជីវករធ្វើការលក់ដូរតែសម្ភារកសិកម្មណាដែលមានប្រភពស្របច្បាប់ត្រឹមត្រូវ ជាសម្ភារកសិកម្មដែលបានចុះបញ្ជិកា និង បានអនុញ្ញាតឱ្យនាំចូលដោយក្រសួង ជាពិសេសត្រូវមានស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរនៅលើសំបកវេចខ្ចប់ជាចាំបាច់ ដើម្បីសម្រួលដល់កសិករអាចយល់ដឹងក្នុងការទិញយកទៅប្រើប្រាស់។

៣-ត្រូវរៀបចំឱ្យមានវគ្គអប់រំស្តីពីបច្ចេកទេសពាក់ព័ន្ធសម្ភារកសិកម្ម ដល់អាជីវករទាំងអស់ដែលស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារកសិកម្មក្នុងមូលដ្ឋានរាជធានី ខេត្ត សាមី ដើម្បីជាលក្ខខណ្ឌផ្នែកសមត្ថភាពវិជ្ជាជីវៈ មុនពេលផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម។

TCT-Introduce to Kompongtom



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

៤-មន្ទីរកសិកម្ម អាចប្រគល់ភារកិច្ចបន្ថែមឱ្យថ្នាក់ដឹកនាំការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ ឱ្យទទួលបន្ទុកជាជំនួយការការងារនីតិកម្ម ដោយសហការសម្របសម្រួលជាមួយការិយាល័យនីតិកម្មកសិកម្មខេត្តក្នុងការបំពេញភារកិច្ចគ្រប់គ្រង ត្រួតពិនិត្យ និង អនុវត្តច្បាប់ចំពោះសកម្មភាពអាជីវកម្មសម្ភារកសិកម្ម ក្នុងដែនសមត្ថកិច្ចសាមី ។

៥-មន្ទីរកសិកម្ម និង ការិយាល័យជំនាញក្រោមឱវាទត្រូវយកចិត្តទុកដាក់ជាចម្បងជំរុញអនុវត្តការងារត្រួតពិនិត្យដោយផ្ទាល់ និង ជាប្រចាំចំពោះមូលដ្ឋានអាជីវកម្ម និង សកម្មភាពធ្វើអាជីវកម្មសម្ភារកសិកម្មគ្រប់ប្រភេទ ដោយពុំត្រូវរារែក ស្ទាក់ស្ទើរ ឬ រង់ចាំលក្ខខណ្ឌផ្សេងៗ ដូចជានីតិសម្បទាជានគរបាលយុត្តិធម៌ ឯកសណ្ឋាន ឬ មធ្យោបាយផ្សេងទៀតឡើយ ពីព្រោះការងារគ្រប់គ្រង និង ការត្រួតពិនិត្យសកម្មភាពធ្វើអាជីវកម្មសម្ភារកសិកម្ម គឺជាសិទ្ធិក្នុងការចាត់វិធានការរដ្ឋបាលរបស់មន្ត្រី ឬ អង្គភាពមានសមត្ថកិច្ចក្នុងក្របខណ្ឌដែនសមត្ថកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលបានកំណត់ក្នុងលិខិតបទដ្ឋានច្បាប់ (អនុក្រឹត្យលេខ ៦៩ អនក្រ.បក ស្តីពីបមាណីយ និង ការគ្រប់គ្រងសម្ភារកសិកម្ម )។

៦-រាល់ការត្រួតពិនិត្យសកម្មភាពអាជីវកម្មសម្ភារកសិកម្ម ដេប៉ូលក់ដុំលក់រាយ ការដឹកជញ្ជូនផ្គត់ផ្គង់ចែកចាយឱ្យបណ្តាដេប៉ូទាំងនោះ ឬ ការដឹកជញ្ជូនលក់បណ្តាក់ដល់ដៃកសិករ ដោយផ្ទាល់នៅមូលដ្ឋានក្តី ការិយាល័យជំនាញត្រូវធ្វើការត្រួតពិនិត្យលើតម្រូវការជាអាទិ៍ដូចខាងក្រោម :

- **លិខិតអនុញ្ញាតធ្វើអាជីវកម្ម**ចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងករណីត្រួតពិនិត្យមូលដ្ឋានអាជីវកម្ម ផលិតកែច្នៃ ឬ វេចខ្ចប់ជាថ្មី (ជាពិសេសជីគីមី) ឃ្លាំង ឬ ដេប៉ូចែកចាយ ដែលផ្គត់ផ្គង់ ចេញក្រៅរាជធានី ខេត្ត សាមី
- **លិខិតអនុញ្ញាតលក់ដុំលក់រាយ** ដែលចេញដោយមន្ទីរកសិកម្ម ចំពោះការត្រួតពិនិត្យដេប៉ូលក់ដុំលក់រាយ នៅក្នុងរាជធានី ខេត្ត សាមី
- **ប័ណ្ណបញ្ចេញឃ្លាំង និង លិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារកសិកម្ម** របស់ក្រុមហ៊ុននាំចូល ឬ ក្រុមហ៊ុនផ្គត់ផ្គង់ចែកចាយណាមួយ ក្នុងករណីអាជីវករបានទទួលទិញពីក្រុមហ៊ុននោះ និង បានដឹកជញ្ជូនសម្ភារកសិកម្មទាំងនោះពីខាងក្រៅរាជធានី ខេត្តចូលមកផ្គត់ផ្គង់ចែកចាយតាមដេប៉ូលក់ដុំលក់រាយ ឬ លក់បណ្តាក់ក្នុងរាជធានី ខេត្ត សាមី
- **ការអនុវត្តបមាណីយ**ចំពោះសំបកវេចខ្ចប់ ស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ និង លេខបញ្ជិកា ដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដោយធ្វើការផ្ទៀងផ្ទាត់ជាមួយព័ត៌មានទិន្នន័យក្នុងឯកសារស្ថិតិ " **លិខិតអនុញ្ញាតធ្វើអាជីវកម្ម ការចុះបញ្ជិកា និង លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្ម** " ដែលបានចងក្រងដោយនាយកដ្ឋាននីតិកម្មកសិកម្ម ហើយដែលក្រសួងបានបញ្ជូន ឱ្យគ្រប់មន្ទីរកសិកម្ម រាជធានី ខេត្ត ប្រើប្រាស់ជាឯកសារមូលដ្ឋានសម្រាប់ធ្វើការត្រួតពិនិត្យសកម្មភាពអាជីវកម្មសម្ភារកសិកម្ម ក្នុងរាជធានី ខេត្ត សាមី ។



7+

៧-ក្នុងករណីសកម្មភាពអាជីវកម្មណាមួយ ល្មើសនឹងបទប្បញ្ញត្តិនៃលិខិតបទដ្ឋានច្បាប់ មន្ត្រីជំនាញមានសមត្ថកិច្ចនៃមន្ទីរកសិកម្ម ត្រូវចាត់វិធានការពិន័យអនុលោមតាមអនុក្រឹត្យលេខ ៦៩ អនក្រ.បក ដោយត្រូវបង្ខំឱ្យធ្វើកិច្ចសន្យាកែតម្រូវ ឬ ចេញលិខិតព្រមានដោយមន្ទីរកសិកម្មក្នុងរយៈពេលកំណត់ ដើម្បីឱ្យអាជីវករ ធ្វើការកែតម្រូវ និង បញ្ឈប់សកម្មភាពល្មើស។

៨-មន្ទីរកសិកម្ម ត្រូវជំរុញអង្គភាពជំនាញ អនុវត្តកម្មវិធី តាមដាន និង ត្រួតពិនិត្យឡើងវិញជាប្រចាំ ចំពោះមូលដ្ឋានអាជីវកម្មនិងអាជីវករដែលបានទទួលវិធានការពិន័យរដ្ឋបាលខាងលើ។ នៅពេលផុតកំណត់នៃវិធានការ មន្ត្រីជំនាញមានសមត្ថកិច្ចត្រូវស្នើដាក់វិធានការបន្តតាមរយៈការចេញលិខិតព្រមានជាលើកចុងក្រោយ ឬ ត្រូវធ្វើបណ្តឹងទៅតុលាការ។

៩-ក្នុងករណីបទល្មើសជាក់ស្តែង ក្លែងគុណភាព ឬ ក្លែងសំបកវេចខ្ចប់សម្ភារកសិកម្ម មន្ទីរកសិកម្ម ចាំបាច់ត្រូវអនុវត្តតាមនីតិវិធីតុលាការ ដោយស្នើសុំការដឹកនាំនីតិវិធីដោយព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត សាមី និង ស្នើសុំកិច្ចសហការពីអាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ និង សមត្ថកិច្ចពាក់ពន្ធ័ធ្វើការចុះត្រួតពិនិត្យ ឆែកឆេរ ឃាត់ទុកវត្ថុតាងបណ្តោះអាសន្ន និង បំពេញសំណុំបែបបទបញ្ជូនទៅតុលាការស្របតាមនីតិវិធី ។

១០-រាល់សកម្មភាពគ្រប់គ្រងសម្ភារកសិកម្មនៅក្នុងរាជធានី ខេត្ត មន្ទីរកសិកម្ម និង ការិយាល័យនីតិកម្មកសិកម្ម ត្រូវសម្របសម្រួលទំនាក់ទំនង និង សហការជាប្រចាំជាមួយនាយកដ្ឋាននីតិកម្មកសិកម្ម លើការងារបច្ចេកទេស និង នីតិវិធីពាក់ពន្ធ័ និង ត្រូវធ្វើរបាយការណ៍ជាប្រចាំនូវលទ្ធផលការងារគ្រប់គ្រងសម្ភារកសិកម្មក្នុងរាជធានី ខេត្ត សាមី ជូននាយកដ្ឋាននីតិកម្មកសិកម្ម ដើម្បីតាមដាន វាយតម្លៃ និង បូកសរុបជូនក្រសួង។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរកសិកម្ម និង ការិយាល័យនីតិកម្មកសិកម្មគ្រប់រាជធានី ខេត្ត ព្រមទាំងការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ ត្រូវទទួលខុសត្រូវ ចាត់ការអនុវត្តតាមវិធានការណែនាំខាងលើឱ្យមានប្រសិទ្ធភាព។

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ មិនា ឆ្នាំ ២០១០

**រដ្ឋមន្ត្រី**

ចាន់-សារុន

**កន្លែងទទួល :**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងយុត្តិធម៌
-សាលាដំបូងរាជធានី ខេត្ត
-គ្រប់សាលារាជធានី ខេត្ត
-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
-ឯកសារ-កាលប្បវត្តិ

TCT-Introduce to Kompongtom